**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**ការិយាល័យអ្នកនាំពាក្យ**

**លេខ ៣០៥ សប្រក**

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី

## ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤

ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤ វេលាម៉ោង ៨:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឆ្លង:

**១-អំពីសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ ។**

**២-អំពីបញ្ហាផ្សេងៗ :**

ក-សេចក្តីជូនពតិមានដល់គណៈរដ្ឋមន្ត្រីអំពីការដែលសម្តេចនាយករដ្ឋមន្ត្រី បានចុះហត្ថលេខាបញ្ជូនសេចក្តីព្រាងច្បាប់ និងកិច្ចព្រមព្រៀងមួយចំនួនដែលរដ្ឋសភានីតិកាលទី ៣ បានបង្វិលមករាជរដ្ឋាភិបាលវិញទៅរដ្ឋសភាជាថ្មីម្តងទៀត

ខ-របាយការណ៍នៃកិច្ចប្រជុំបច្ចេកទេស និងប្រជុំក្រៅផ្លូវការរបស់ប្រមុខមុខងារសាធារណៈអាស៊ាន ក្នុងក្របខ័ណ្ឌនៃសន្និសីទអាស៊ាន ស្តីពីកិច្ចការមុខងារសាធារណៈលើកទី ១២ នៅប្រទេសប្រ៊ុយណេដារូសាឡឹម

ក្រោយពីបានពិភាក្សានិងផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានសំរេច :

### I- អំពីសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ

គណៈរដ្ឋមន្ត្រីបានឯកភាព និងអនុម័តសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជាជាសហគ្រាសសាធារណៈដែលត្រូវបានក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ផ្តួចផ្តើមគំនិត និងសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំឡើងក្នុងគោលបំណងធ្វើអោយស្របតាមលក្ខខ័ណ្ឌតំរូវរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ដោយមានលក្ខណៈជាក្រុមហ៊ុនរដ្ឋស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

### II-អំពីបញ្ហាផ្សេងៗ

ក-គណៈរដ្ឋមន្ត្រីបានឯកភាពបញ្ជូនសេចក្តីព្រាងច្បាប់ និងកិច្ចព្រមព្រៀងចំនួន ១០ ដាក់ជូនរដ្ឋសភា ដែលក្នុងនោះរួមមាន :

១-សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីអាវុធគីមី

២-សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពីបត្យាប័ន

៣-សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងធនធានទឹក ក្នុងព្រះរាជាណាចក្រកម្ពុជា

៤-សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីទំនាក់ទំនងកុងស៊ុល

៥-សេចក្តីព្រាងច្បាប់ ស្តីពីស្ថិតិ

៦-សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់គ្រប់គ្រងឆ្នាំ ២០០១

៧-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើធម្មនុញ្ញអង្គការអន្តរជាតិទេសន្តរប្រវេសន៏

៨-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមអោយព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់

៩-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមអោយព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញាស្តីពីសារធាតុដែលធ្វើអោយប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ ១៩៧១

១០-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមអោយព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញាទោលស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១ ។

ខ-ពាក់ព័ន្ធលើរបាយការណ៍នៃកិច្ចប្រជុំបច្ចេកទេស និងប្រជុំក្រៅផ្លូវការរបស់ប្រមុខ មុខងារសាធារណៈអាស៊ាន ក្នុងក្របខ័ណ្ឌនៃសន្និសីទអាស៊ានស្តីពីកិច្ចការមុខងារសាធារណៈលើកទី ១២ នៅប្រទេសប្រ៊ុយណេដារូសាឡឹម ដែលរាយ-ការណ៍ដោយ ឯកឧត្តម **ពេជ្រ ម៉ិនធិន** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គណៈរដ្ឋមន្ត្រីបានឯកភាពរៀបចំសន្និសីទអាស៊ានលើកទី ១៣ ស្តីពីកិច្ចការមុខងារសាធារណៈនៃប្រទេសអាស៊ាន ដែលនឹងប្រព្រឹត្តទៅនៅព្រះរាជា-ណាចក្រកម្ពុជានាឆ្នាំ ២០០៥-២០០៦ ក្រោមប្រធានបទ : ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យ មុខងារសាធារណៈ ជាដៃគូយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍន៍ "**គំនិតថ្មីសំរាប់បរិបទអាស៊ាន**" ។

ក្រោយពីបានស្តាប់នូវសេចក្តីរាយការណ៍របស់ ឯកឧត្តម **ញឹម វណ្ណដា** ទេសរដ្ឋមន្ត្រី និងជាអនុប្រធានទី ១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយស្តីពីស្ថានភាពរាំងស្ងួតនៅចុងរដូវវស្សាកន្លងមកនេះ សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ណែនាំអោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិលុបចោលនូវកម្មវិធីដំណើរទស្សនកិច្ចរបស់សម្តេចទៅប្រទេសក្រៅមួយចំនួន ដើម្បីទុកពេលវេលាជូនសម្តេចនាយករដ្ឋមន្ត្រីចុះមូលដ្ឋានជំរុញការបូមទឹក លើកទំនប់ ជីកប្រឡាយ ជួយសង្គ្រោះ និងលើកស្ទួយជីវភាពប្រជាពលរដ្ឋពីពេលនេះរហូតដល់ពេលបញ្ចប់ការប្រមូលផលរដូវវស្សាឆ្នាំ ២០០៥ ខាងមុខ ។

អង្គប្រជុំគណៈរដ្ឋមន្ត្រីបានបិទសម័យប្រជុំនៅម៉ោង ១១ និង ៥៥ នាទី ។

ភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ២០០៤